NEWS RELEASE

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

# អាស៊ី-ប៉ាស៊ីហ្វិក៖ អ្នកស្រី បាស្លេទ្បេត មានការព្រួយបារម្ភចំពោះការគាបសង្កត់លើ សេរីភាពក្នុងការបញ្ចេញមតិទាក់ទងនឹងជំងឺកូវីដ-១៩

ទីក្រុងហ្សឺណែវ (០៣ មិថុនា ២០២០) - ឧត្តមស្នងការសិទ្ធិមនុស្ស អ.ស.ប អ្នកស្រី មីស្សែល បាស្លេទ្បេត បានសម្តែងការព្រួយបារម្ភ ចំពោះការគាបសង្កត់លើសេរីភាពនៃការបញ្ចេញមតិ នៅផ្នែកខ្លះនៃតំបន់អាស៊ីប៉ាស៊ីហ្វិក នៅក្នុងអំឡុងពេលមានវិបត្តិនៃជំងឺកូវីដ-១៩ ដោយមានប្រសាសន៍ថា វិធានការទាំងឡាយណាដែលធ្វើឡើង ដើម្បីបញ្ឈប់ការផ្សព្វផ្សាយព័ត៌មានមិនពិត ត្រូវតែមានសមាមាត្រ។

ប្រទេសជាច្រើននៅក្នុងតំបន់មានរួចហើយនូវច្បាប់គ្រប់គ្រង ដែលគេហៅថា " ព័ត៌មានមិនពិត " និងប្រព័ន្ធផ្សព្វផ្សាយតាមអនឡាញដែលលើកឡើង ពីកង្វល់អំពីសិទ្ធិមនុស្ស ហើយត្រូវបានគេប្រើប្រាស់ក្នុងបរិបទផ្សេងទៀត ដើម្បីរារាំងការនិយាយស្តីស្របច្បាប់ ជាពិសេស ការជជែកដេញដោលជាសាធារណៈ ការរិះគន់អំពីគោលនយោបាយរបស់រដ្ឋាភិបាលនិងការបង្ក្រាបសេរីភាពក្នុងការបញ្ចេញមតិ។

អ្នកស្រី បាស្លេទ្បេត បានមានប្រសាសន៍ថា ជំងឺកូវីដ-១៩ ត្រូវបានគេមើលឃើញពីការរឹតត្បិតបន្ថែមទៀតលើការនិយាយស្តីនៅប្រទេសជាច្រើន អមដោយការចាប់ខ្លួន និងការឃុំខ្លួនអ្នកទាំងឡាយនិយាយរិះគន់ ចំពោះការឆ្លើយតបរបស់រដ្ឋាភិបាល ឬគ្រាន់តែការចែករំលែកព័ត៌មាន ឬទស្សនៈអំពីជំងឺរាតត្បាតនេះ។

ការចាប់ខ្លួនដោយសារតែការបង្ហាញមតិមិនពេញចិត្ត ឬដែលអះអាងថាបានផ្សព្វផ្សាយព័ត៌មានមិនពិតតាមរយៈសារព័ត៌មាន និងបណ្តាញសង្គម ត្រូវបានគេរាយការណ៍ថាមាននៅប្រទេសបង់ក្លាដែស កម្ពុជា ចិន ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី មីយ៉ាន់ម៉ា នេប៉ាល់ ហ្វីលីពីន ស្រីលង្កា ថៃ និងវៀតណាម។

ឧត្តមស្នងការបានទទួលស្គាល់ពីភាពចាំបាច់ក្នុងការទប់ស្កាត់ព័ត៌មានក្លែងក្លាយ ឬព័ត៌មានមិនពិតដែលបង្កគ្រោះថ្នាក់ដល់សុខភាពសាធារណៈ ឬការញុះញង់ឱ្យមានការខឹងស្អប់ចំពោះក្រុមជនជាតិភាគតិចផ្សេងៗ ប៉ុន្តែថា ការនេះមិនគួរបណ្តាលឱ្យមានការរឹតត្បិតលើការបញ្ចេញមតិផ្ទាល់ខ្លួនដោយមានបំណង ឬដោយអចេតនា ដែលធ្វើឱ្យបាត់បង់ការជឿទុកចិត្តឡើយ។ " ទោះបីជារដ្ឋាភិ-បាលទាំងឡាយ មានផលប្រយោជន៍ស្របច្បាប់ ក្នុងការគ្រប់គ្រងការផ្សព្វផ្សាយព័ត៌មានមិនពិត ក្នុងបរិបទដែលងាយនឹងបង្កជាហេតុ និងងាយរងគ្រោះនេះក៏ដោយ ក៏ផលប្រយោជន៍ស្របច្បាប់នោះ ត្រូវតែមានសមាមាត្រ និងការពារសេរីភាពក្នុងការបញ្ចេញមតិផងដែរ" អ្នកស្រី បាស្លេទ្បេត បានមានប្រសាសន៍យ៉ាងដូច្នេះ។

**នៅប្រទេសបង់ក្លាដែស** មានសេចក្តីរាយការណ៍ថា មនុស្សរាប់សិបនាក់ មានករណីបណ្តឹងចោទប្រកាន់មកលើខ្លួន ឬត្រូវបានចាប់ខ្លួន ក្រោមច្បាប់សន្តិសុខឌីជីថល ក្នុងរយៈពេលត្រឹមតែបីខែមកនេះ ពីបទផ្សព្វផ្សាយព័ត៌មានមិនពិត អំពីជំងឺកូវីដ-១៩ ឬរិះគន់ចំពោះការឆ្លើយតបរបស់រដ្ឋាភិបាល។ អ្នកសារព័ត៌មានក្នុងស្រុក និងអ្នកការពារសិទ្ធិមនុស្ស អ្នកជំនាញផ្នែកសុខភាពមួយចំនួន ក៏ដូចជាសមាជិកនៃសាធារណជនខ្លះទៀត បានរាយការណ៍អំពីការយាយីរំខាន ឬការសងសឹក ដោយសារតែការត្អូញត្អែរអំពីការបដិសេធកិច្ចគាំពារសុខភាព សេវាមិនគ្រប់គ្រាន់ ឬភាពមិនប្រក្រតីក្នុងការចែកចាយជំនួសសង្គ្រោះ។ ក្នុងករណីខ្លះ អ្នកសារព័ត៌មាន ឬអ្នកសង្កេតការណ៍ផ្សេងទៀត ត្រូវបានគេវាយធ្វើបាបលើរូបកាយ ព្រោះតែការស្វែងរកឯកសារដែលអះអាងពីទង្វើខុសឆ្គង។

**នៅប្រទេសកម្ពុជា** ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យ OHCHR) បានចងក្រងជាឯកសារទាក់ទងនឹងការចាប់ខ្លួនមនុស្សចំនួន ៣០ នាក់ រាប់ទាំងស្ត្រីប្រាំមួយ នាក់ និងក្មេងស្រីម្នាក់អាយុ ១៤ ឆ្នាំ ដោយសារតែការនិយាយអធិប្បាយជាសាធារណៈ និងការបង្ហោះលើបណ្តាញសង្គមទាក់ទងនឹងជំងឺកូវីដ-១៩។ មនុស្សមួយចំនួន ត្រូវបានចោទប្រកាន់ពីបទផ្សព្វផ្សាយព័ត៌មានមិនពិត ឬព័ត៌មានក្លែងក្លាយ ការញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ និងរៀបចំផែនការប្រឆាំងនឹងរដ្ឋាភិបាល។ មនុស្សចំនួនដប់បួននាក់ កំពុងស្ថិតក្នុងការឃុំខ្លួននៅឡើយ ក្នុងនោះ ១០ នាក់ ជាប់ពាក់ព័ន្ធនឹងគណបក្សសង្គ្រោះជាតិ ដែលត្រូវបានប្រកាសរំលាយហើយនោះ។

**នៅប្រទេសចិន** ការិយាល័យសិទ្ធិមនុស្ស អ.ស.ប បានទទួលព័ត៌មានអំពីករណីជាច្រើននៃអ្នកជំនាញវេជ្ជសាស្ត្រ សាស្ត្រាចារ្យ និងពលរដ្ឋសាមញ្ញជាច្រើននាក់ ដែលទំនងជាត្រូវបានឃុំខ្លួន ហើយក្នុងករណីខ្លះ ត្រូវបានចោទប្រកាន់ពីបទផ្សព្វផ្សាយពីទស្សនៈរបស់ខ្លួន ឬព័ត៌មានផ្សេងទៀត អំពីស្ថានភាពទាក់ទងនឹងជំងឺកូវីដ-១៩ ឬអ្នកដែលរិះគន់ចំពោះការឆ្លើយតបរបស់រដ្ឋាភិបាលទៅនឹងការផ្ទុះឡើងនៃជំងឺនេះ។ ករណីទាំងនេះ រួមមាន និស្សិតវ័យក្មេងពីររូប ដែលទើបនឹងបញ្ចប់ការសិក្សា ដែលត្រូវបានគេរាយការណ៍ថាត្រូវបានឃុំខ្លួនក្នុងខែមេសា បន្ទាប់ពីបានបង្កើតកន្លែងរក្សាទុកមាតិកាលើវិបសាយ ឬអ៊ីនធឺណិត ដែលទាក់ទងនឹងការផ្ទុះឡើងនៃជំងឺកូវីដ-១៩ នៅក្នុងប្រទេសចិន។

**នៅប្រទេសឥណ្ឌា** អ្នកកាសែតមួយចំនួន និងយ៉ាងហោចណាស់ ក៏មានវេជ្ជបណ្ឌិតម្នាក់ដែរ ត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌ ដោយសារតែពួកគេរិះគន់ជាសាធារណៈចំពោះការឆ្លើយតបរបស់អាជ្ញាធរចំពោះជំងឺកូវីដ-១៩។ នៅទីក្រុងបុមបៃ នគរបាលបានចេញបទបញ្ជាហាមឃាត់ "ជនណាដែលញុះញង់មិនឲ្យជឿទុកចិត្តលើមន្ត្រីរដ្ឋាភិបាល និងវិធានការរបស់ពួកគេ ក្នុងបង្ការទប់ស្កាត់

ការរីករាលដាលនៃជំងឺកូវីដ-១៩ ហើយដោយហេតុនេះ បង្កគ្រោះថ្នាក់ដល់សុខភាព ឬសុវត្ថិភាពមនុស្ស ឬការរំខានដល់ភាពស្ងប់ស្ងាត់ជាសាធារណៈ″។

**នៅប្រទេសឥណ្ឌូនេស៊ី** មានមនុស្សយ៉ាងហោចណាស់ ៥១ នាក់ ត្រូវបានគេរាយការណ៍ថា កំពុងស្ថិតក្រោមស៊ើបសួរ ក្រោមច្បាប់បរិហារកេរ្តិ៍ជាបទព្រហ្មទណ្ឌ ដោយចោទពីបទផ្សព្វផ្សាយ " ព័ត៌មានមិនពិត ″ អំពីការឆ្លងរាតរាលនៃជំងឺនេះ រាប់ទាំងបុរសបី នាក់ ដែលត្រូវបានចាប់ខ្លួន ពីបទបង្ហោះសារនៅលើបណ្ដាញសង្គម ដោយអះអាងថា តំបន់មួយនៅទីក្រុងហ្សាកាតាភាគខាងជើង មានករណីជំងឺកូវីដ-១៩ បន្ទាប់ពីរដ្ឋាភិបាល បានបាញ់ថ្នាំសម្លាប់មេរោគនៅទីនោះ។ មានសេចក្ដីរាយការណ៍ផងដែរថា នគរបាលបានបិទគណនីបណ្ដាញសង្គមជាច្រើន ។

**នៅប្រទេសម៉ាឡេស៊ី** អ្នកឆ្លើយឆ្លងព័ត៌មានជាតិ នៃកាសែត South China Morning Post ដែលមានមូលដ្ឋាននៅទីក្រុងហុងកុង កំពុងស្ថិតក្នុងការស៊ើបសួរ ចំពោះករណីប្រើប្រាស់មធ្យោបាយ ឬសេវាមិនត្រឹមត្រូវ និងការជេរប្រមាថដោយចេតនា ដែលមានបំណងបង្កឱ្យមានការរំលោភបំពានសន្តិភាព ព្រោះតែការរាយការណ៍អំពីការឃុំខ្លួនជនចំណាកស្រុកដែលគ្មានឯកសារ ដែលបានរាយការណ៍ថា ទោះជាមានសេចក្ដីណែនាំរបស់ក្រសួង មិនឱ្យចាត់វិធានការទៅលើអ្នកនាំពាក្យក្ដី ។

**នៅប្រទេសភូមា** នៅថ្ងៃ៣ មេសា សិល្បករបីនាក់ នៅរដ្ឋកាឈិន ត្រូវបានចោទប្រកាន់ពីបទគូរផ្ទាំងរូបភាពលើជញ្ជាំងអំពីជំងឺកូវីដ-១៩ ដែលគេចាត់ទុកថា ជាការប្រមាថដល់ព្រះពុទ្ធសាសនា។ នៅថ្ងៃទី២១ ឧសភា តុលាការរដ្ឋកាយិន បានសម្រេច និងផ្ដន្ទាទោសដាក់ពន្ធនាគាររយៈពេល ២ ឆ្នាំ និពន្ធនាយកនៃទីភ្នាក់ងារសារព័ត៌មាន Dae Pyaw ពីបទធ្វើ " សេចក្ដីថ្លែងការណ៍ដែលអាចបង្ក ឬញុះញង់ឱ្យមានការភ័យខ្លាច ឬការបះបោរជាសាធារណៈ″ ។ បណ្ដាញព័ត៌មានបានចុះផ្សាយអត្ថបទមួយ នៅថ្ងៃទី១៣ ឧសភា ដោយបានបញ្ជាក់ថា មនុស្សម្នាក់បានស្លាប់នៅរដ្ឋកាយិន ដោយសារវីរុស ដែលក្រោយមកព័ត៌មាននេះប្រែជារឿងមិនពិតទៅវិញ។ គាត់ត្រូវបានចាប់ខ្លួន ចោទប្រកាន់ ជំនុំជម្រះ និងផ្ដន្ទាទោសដាក់ពន្ធនាគាររយៈពេលក្រោមមួយសប្ដាហ៍។

**នៅប្រទេសនេប៉ាល់** អាជ្ញាធរបានប្រើច្បាប់ឧក្រិដ្ឋកម្មតាមអ៊ីនធឺណិតយ៉ាងតឹងរ៉ឹង ដើម្បីចាប់ខ្លួនអ្នកប្រជាធិបតេយ្យចូលនិវត្តន៍មួយរូប ដែលរិះគន់រដ្ឋាភិបាល រួមទាំង ការឆ្លើយតបរបស់រដ្ឋាភិបាលទៅនឹងជំងឺកូវី-១៩។ យោងតាម ក្រុមសេរីភាពសារព័ត៌មាន បានឱ្យដឹងថា មានករណីអ្នកសារព័ត៌មានជាច្រើនត្រូវបានឃុំខ្លួន ដោយសារតែពួកគេចុះផ្សាយព័ត៌មានទាក់ទងនឹងជំងឺកូវីដ ឧប្បត្តិហេតុដែលអ្នកសារព័ត៌មានប្រឈមនឹងការរាំងពីអាជ្ញាធរ និងសេចក្ដីរបាយការណ៍អំពីការគំរាមកំហែង និងការវាយប្រហារលើរាងកាយ។

នៅ**ប្រទេសហ្វីលីពីន** ការចាប់ខ្លួន ត្រូវបានធ្វើឡើង ក្រោមច្បាប់អំណាចពិសេសនៃជំងឺកូវីដថ្មី ដែលដាក់ជាបទឧក្រិដ្ឋនូវការផ្សាយព័ត៌មានមិនពិត។ ទាំងនេះ រាប់ទាំង សិល្បករម្នាក់នៅសេប៊ូ ចំពោះមតិដែលគាត់បានអធិប្បាយតាមអនឡាញ អំពីអត្រាប្រេវ៉ាឡង់នៃការឆ្លងនៅតំបន់មួយ។ ក្រសួងរដ្ឋាភិបាលមួយ ក៏បានស្វែងរកការធ្វើនិរទេសពលករចំណាកស្រុកជនជាតិហ្វីលីពីនម្នាក់ នៅបរទេស ដោយសារតែគាត់/នាង បានអធិប្បាយរិះគន់តាមអនឡាញ។

នៅ**ប្រទេសស្រីលង្កា** អគ្គស្នងការស្តីទីនៃស្នងការដ្ឋាននគរបាល បានគំរាមចាប់ខ្លួនជនណា ដែលរិះគន់ ឬលើកឡើងពី "កំហុសឆ្គងតូចតាច" របស់មន្ត្រីទាំងឡាយ ពាក់ព័ន្ធនឹងការឆ្លើយតបទៅនឹងកូរ៉ូណាវីរុស ឬអ្នកដែលចែករំលែកសារ " ក្លែងក្លាយ " ឬ សារដែលមានចរិត " ព្យាបាទ " ។ គណៈកម្មការសិទ្ធិមនុស្សនៃប្រទេសស្រីលង្កា នៅថ្ងៃ២៥ មេសា បានសរសេរលិខិតមួយច្បាប់ ទៅនគរបាល ដោយបញ្ជាក់ប្រាប់ថា រាល់ការចាប់ខ្លួន ដោយការគ្រាន់តែរិះគន់មន្ត្រីសាធារណៈ ឬគោលនយោបាយសាធារណៈ គឺអធម្មនុញ្ញភាព។ មានមនុស្សជាច្រើន ត្រូវបានចាប់ខ្លួន ដោយសារតែការបង្ហោះលើទំព័រហ្វេសប៊ុករបស់ខ្លួន។

នៅ**ប្រទេសថៃ** មជ្ឈមណ្ឌលប្រឆាំងព័ត៌មានក្លែងក្លាយ នៃក្រសួងសេដ្ឋកិច្ចឌីជីថល និងសង្គម និងអង្គភាពបង្ក្រាបឧក្រិដ្ឋកម្មបច្ចេកវិទ្យា នៃរាជនគរបាលថៃ បាននិងកំពុងធ្វើប្រតិបត្តិការរួមគ្នា ដើម្បីដោះស្រាយមាតិកាប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលចាត់ទុកថាជាការផ្សព្វផ្សាយព័ត៌មានមិនពិត ក្នុងបរិបទនៃជំងឺកូវីដ-១៩។ មានការព្រួយបារម្ភថា ប្រជាជនដែលលើកឡើងពីបញ្ហាស្របច្បាប់ដែលជាផលប្រយោជន៍សាធារណៈទាក់ទងនឹងជំងឺកូវីដ-១៩ ក៏ត្រូវគេកំណត់ជាគោលដៅផងដែរ ហើយសកម្មភាពបែបនេះ អាចបង្កើតបរិយាកាសរិតត្បិតលើការនិយាយស្តីដោយខ្លួនឯង។ ឧទាហរណ៍មួយគឺវិចិត្រករជនជាតិថៃមួយរូប ត្រូវបានចាប់ខ្លួន នៅថ្ងៃ២៣ មេសា ពីបទបង្ហោះសារបង្ហាញពីការព្រួយបារម្ភអំពីកង្វះវិធានការជាក់ស្តែង ក្នុងការត្រួតពិនិត្យនៅអាកាសយានដ្ឋានសុវណ្ណភូមិ នៅខណៈពេលដែលគាត់មកពីបរទេស មកដល់អាកាសយានដ្ឋាននេះ នៅថ្ងៃ ១៦ មេសា។ ក្រោយមកគាត់ត្រូវបានដោះលែងឱ្យនៅក្រៅឃុំវិញ តែពេលនេះ ត្រូវបានចោទប្រកាន់ហើយ។

ចាប់តាំងពីកើតមានជំងឺរាតត្បាតមក អាជ្ញាធរក្នុង**ប្រទេសវៀតណាម** បានរាយការណ៍ថា បានកោះហៅអ្នកប្រើហ្វេសប៊ុកជាង ៦០០ នាក់ មកធ្វើការសាកសួរ ពាក់ព័ន្ធនឹងការបង្ហោះតាមអនឡាញអំពីការផ្ទុះវីរុសនេះ។ អ្នកទាំងនោះ ភាគច្រើនបានទទួលទណ្ឌកម្មរដ្ឋបាល ហើយអត្ថបទ ឬរូបភាពជាច្រើនដែលបានបង្ហោះ ត្រូវបានលប់ចោល។ រហូតមកទល់ថ្ងៃនេះ យ៉ាងហោចណាស់ ក៏មានអ្នកប្រើហ្វេសប៊ុកចំនួនពីរម្នាក់ដែរ ត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌ ព្រោះតែការបង្ហោះព័ត៌មានដែលទំនងជា

មិនពិតអំពីជំងឺកូវីដ-១៩ រាប់ទាំងទោសជាប់ពន្ធនាគាររយៈពេលប្រាំបួនខែ និងពិន័យជាប្រាក់ជាង ១.០០០ ដុល្លារ អាមេរិក)។ កង្វល់កន្លងមក នៅតែមាន អំពីភាពធ្ងន់ធ្ងរនៃការរឹតត្បិត និងការកាត់ទោសក្នុងករណីដែលទាក់ទងនឹងសិទ្ធិប្រើប្រាស់សេរីភាពក្នុងការបញ្ចេញមតិតាមអនឡាញ និងតាមអូហ្វឡាញ។

"នៅក្នុងគ្រាលំបាកដែលមិនច្បាស់លាស់នេះ អ្នកជំនាញវេជ្ជសាស្ត្រ អ្នកកាសែត អ្នកការពារសិទ្ធិមនុស្ស និងសាធារណជនទូទៅ ត្រូវតែបានអនុញ្ញាតឱ្យបញ្ចេញមតិយោបល់លើប្រធានបទសំខាន់ៗ ដែលជាផលប្រយោជន៍សាធារណៈ ដូចជា ការផ្តល់កិច្ចគាំពារសុខភាព និងការគ្រប់គ្រងវិបត្តិសុខភាព និងសេដ្ឋកិច្ចសង្គម និងការចែកចាយជំនួយសង្គ្រោះ"។ នេះបើតាមប្រសាសន៍របស់អ្នកស្រីបាសេឡេត ។

"វិបត្តិនេះ មិនគួរត្រូវបានប្រើប្រាស់ ដើម្បីរឹតត្បិតមតិប្រឆាំង ឬលំហូរដោយសេរី នៃព័ត៌មាន និងការជជែកដេញដោលឡើយ។ ចម្រុះភាពនៃទស្សនៈ នឹងជំរុញឱ្យមានការយល់ដឹងកាន់តែច្រើនថែមទៀត អំពីបញ្ហាប្រឈមផ្សេងៗ ដែលយើងជួបប្រទះ និងជួយយើងឱ្យរិតតែជំនះបាននូវបញ្ហាទាំងនោះ។ វាក៏ជួយប្រទេសនានា ឱ្យមានការជជែកដេញដោលដ៏រស់រវើក អំពីឫសគល់នៃបញ្ហា និងការអនុវត្តល្អៗ ដែលចាំបាច់ ដើម្បីជំនះផលប៉ះពាល់ខាងសេដ្ឋកិច្ចសង្គមរយៈពេលវែង និងផលប៉ះពាល់ដទៃផ្សេងទៀត។ ការជជែកដេញដោលនេះមានសារៈសំខាន់សម្រាប់ប្រទេសទាំងឡាយក្នុងការកសាងស្តារឡើងវិញបន្ទាប់ពីមានវិបត្តិ។"

ចប់